# ទ្រព្យសម្បត្តិទទួលខុសត្រូវ

## (ការអនុវត្តដោយបង្ខំ)

*ស៊ិន សៀងហេង*
សិស្សអាជ្ញាសាលាជំនាន់ទី ១
នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ

# ទ្រព្យសម្បត្តិទទួលខុសត្រូវ

- គោលគំនិត
- វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ
- ការទទួលខុសត្រូវដោយមានកម្រិត

# គោលគំនិត

- ការអនុវត្តដោយបង្ខំ គឺជានីតិវិធីតាមផ្លូវតុលាការ ក្នុងការសម្រេចនូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគ ដែលបានកំណត់ក្នុងនីតិឯកជនដោយប្រើអំណាចរដ្ឋ។

- ដូច្នេះអាចនិយាយបានថា គោលបំណងនៃការអនុវត្តដោយបង្ខំ គឺដើម្បីផ្តល់ឱ្យម្ចាស់បំណុល នូវភាពស្ងប់ចិត្ត ដោយអំណាចរដ្ឋ ដូចក្នុងករណីដែលកូនបំណុលបានអនុវត្តនូវកាតព្វកិច្ចរបស់ខ្លួនដែរ។

- ទ្រព្យសម្បត្តិដែលអាចសម្រេចនូវសិទ្ធិទាមទារ បាន គឺទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យសម្បត្តិដែលនៅក្រោមការគ្រប់គ្រងរបស់កូនបំណុល។

# គោលគំនិត (ត)

- ទ្រព្យសម្បត្តិដែលអាចសម្រេចនូវសិទ្ធិប្រាតិភោគបាន នោះគឺជាជាទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃសិទ្ធិប្រាតិភោគ ដែលពាក់ព័ន្ធនោះ។

- ទ្រព្យសម្បត្តិដែលអាចសម្រេចបាននូវសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគខាងលើ ហៅថា "*ទ្រព្យសម្បត្តិទទួលខុសត្រូវ*" នៃសិទ្ធិទាមទារ ឬ សិទ្ធិប្រាតិភោគនោះ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ

- ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវជាទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់កូនបំណុល ឬ ទ្រព្យដែលស្ថិតក្រោមការគ្រប់គ្រងរបស់កូនបំណុលនៃការអនុវត្ត នៅពេលចាប់ផ្តើមធ្វើការអនុវត្តដោយបង្ខំ។
- ចំពោះការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់៖ ជាគោលការណ៍ នៅពេលចាប់ផ្តើមការអនុវត្តដោយបង្ខំទ្រព្យសម្បត្តិទាំងអស់ដែលជាកម្មសិទ្ធិរបស់កូនបំណុល (ទ្រព្យសម្បត្តិទូទៅ) គឺជាទ្រព្យសម្បត្តិទទួលខុសត្រូវ លើកលែងតែមានបញ្ញត្តិពិសេស ឬ ច្បាប់ផ្សេង (ម. ៣៧៩) ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ករណីអញ្ញត្រកម្ម៖ មិនត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិទទួលខុសត្រូវទេ ទោះបីជាទ្រព្យសម្បត្តិនោះជាកម្មសិទ្ធិរបស់កូនបំណុលក៏ដោយ ប្រសិនជា វត្ថុនោះមិនអាចចាត់ចែងប្តូរជាប្រាក់បានតាមចក្ខុវិស័យរបស់ច្បាប់ ឬ ទ្រព្យដែលច្បាប់បានហាមឃាត់មិនឱ្យរឹបអូស ឬ ទ្រព្យសម្បត្តិដែលលើសពីសិទ្ធិទាមទារ ឬ ទ្រព្យសម្បត្តិដែលប៉ាន់ប្រមាណថាគ្មានចំនួនសេសសល់បន្ទាប់ពីបង់សោហ៊ុយសម្រាប់នីតិវិធី ឬ សិទ្ធិ ឬ ទ្រព្យសម្បត្តិរបស់តតិយជន ជាអាទ៍។
- វត្ថុមិនអាចចាត់ចែងប្តូរជាប្រាក់បាន តាមចក្ខុវិស័យរបស់ច្បាប់ ៖ រួមមាន រូបិយវត្ថុក្លែងក្លាយ ឬ វត្ថុដែលប៉ាន់ប្រមាណថាមិនអាចលក់កើត ទោះក្នុងលក្ខខ័ណ្ឌដែលអនុវត្តលក់តាមវិធីសមរម្យក៏ដោយ (ម. ៣៩៣)

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ទ្រព្យដែលច្បាប់បានហាមឃាត់មិនឱ្យរឹបអូស អាចជា ចលនវត្ថុ ឬ សិទ្ធិលើបំណុល ឬ ករណីដែលមានដីកាសម្រេចលុបចោលការរឹបអូស។
- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០)រួមមាន៖
  ក. ប្រដាប់ស្លៀកពាក់ ប្រដាប់សម្រាប់ដំណេក តុ ទូ ប្រដាប់ សម្រាប់ដាំស្ល និង ប្រដាប់សម្រាប់បិទឃាំងបន្ទប់ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០) រួមមាន៖

ខ. គ្រឿងឧបភោគបរិភោគ និង ទបហានវត្ថុនៃការអនុវត្ត ដែលត្រូវការចាំបាច់ដើម្បីចិញ្ចឹមជិវិត ក្នុងអំឡុងពេល ២ (ពីរ) ខែ របស់កូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

គ. របបឧបត្ថម្ភជិវិត របបឧបត្ថម្ភផ្នែកអប់រំ របបឧបត្ថម្ភសុខភាព និង ប្រាក់ឧបត្ថម្ភផ្សេងទៀតដែលផ្តល់ពីរដ្ឋ ឬ ពីអាជ្ញាធរដែនដី ដើម្បីការពារជីវភាពរបស់កូនបំណុលនៃការអនុវត្ត។

ឃ. ផ្នែកប្រាក់តិចជាង ឬ ស្មើនឹង ១,០០០,០០០ (មួយលាន) រៀល ក្រៅពីប្រាក់ដែលបានកំណត់ក្នុងចំណុច គ ខាងលើនេះ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០) រួមមាន៖

ង. ឧបករណ៍ ជី សត្វពាហនៈដែលជាចាំបាច់សម្រាប់ការងារកសិកម្ម របស់ខ្លួន និងចំណីសត្វទាំងនោះ ព្រមទាំងគ្រាប់ពូជ ឬ កសិផល ដែលមានប្រភេទដូចគ្នា ដែលត្រូវការជាចាំបាច់សម្រាប់បន្ត ការងារកសិកម្មរហូតដល់រដូវដែលផលបន្ទាប់ របស់កសិករក្នុង ការប្រកបការងារកសិកម្ម។

ច. មង សំណាញ់ ឬ នេសាទុបករណ៍ផ្សេងៗចាំបាច់ ចំណី និង កូន ត្រី ឬ ជលផលប្រភេទដូចគ្នា ដែលត្រូវការចាំបាច់សម្រាប់រកជល ផល ឬ ចិញ្ចឹមជលផលរបស់អ្នកប្រកបរបរនេសាទ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០) រួមមាន៖

ឆ. ឧបករណ៍ និង វត្ថុផ្សេងទៀតដែលចាំបាច់សម្រាប់អ្នកបច្ចេកទេស សិប្បករ កម្មករ និង អ្នកផ្សេងទៀតដែលប្រកបរបរវិជ្ជាជីវៈ ឬ សាជីវកម្ម ដោយប្រើកម្លាំងប្រាជ្ញា កម្លាំងកាយ ។ ប៉ុន្តែបើវត្ថុដែលអ្នកនោះមានក្នុងគោលបំណងសម្រាប់លក់ ឬ ជួលវិញ អាចរឹបអូសបាន។

ជ. ព្រះពុទ្ធរូប ក្បួនរីតិ៍សាសនា និង វត្ថុផ្សេងៗទៀតដែលចាំបាច់សម្រាប់ពិធីក្នុងសាសនា។

ឈ. ពង្សាវលី កំណត់ប្រចាំថ្ងៃ បញ្ជីប្រកបមុខរបរ និង ឯកសារប្រភេទដូចគ្នាដែលចាំបាច់របស់កូនបំណុលនៃការអនុវត្ត។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០)រួមមាន៖

ញ. គ្រឿងឥស្សរិយយស និង បណ្ណសរសើរផ្សេងៗទៀតរបស់កូនបំណុលនៃការអនុវត្ត ឬរបស់ញាតិរបស់ជននោះ។

ដ. ឯកសារ និង ឧបករណ៍ដែលចាំបាច់ក្នុងការសិក្សា នៅសាលា ឬ នៅស្ថាប័នអប់រំផ្សេងទៀត របស់កូនបំណុលនៃការអនុវត្ត ឬ ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។

ឋ. វត្ថុដែលទាក់ទងនឹងតក្កកម្ម ឬ ស្នាដៃនិពន្ធ ដែលមិនទាន់ផ្សាយជាសាធារណៈ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ចលនវត្ថុដែលហាមឃាត់មិនឱ្យរឹបអូស (ម. ៣៨០)រួមមាន៖
  - ឌ. អវយវៈសិប្បនិមិត្ត សរីរាងសិប្បនិមិត្តផ្សេងទៀត និង ឧបករណ៍ជំនួយខ្លួនប្រាណផ្សេងទៀត ដែលចាំបាច់សម្រាប់កូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា ព្រមទាំងវត្ថុផ្សេងៗសម្រាប់ថៃទាំ អ្នកជម្ងឺ ដែលជាកូនបំណុលនៃការអនុវត្ត និង ញាតិដែលរស់នៅជាមួយកូនបំណុលនៃការអនុវត្ត ហើយមានជីវភាពរួមគ្នា។
  - ឍ. ម៉ាស៊ីន ឬ ឧបករណ៍ពន្លត់ភ្លើង ឧបករណ៍ជន្លៀសខ្លួនពេលមានអាសន្ន ឧបករណ៍ផ្សេងទៀតដែលច្បាប់ ឬ បទដ្ឋានគតិយុត្តផ្សេងៗ តម្រូវឱ្យមានបរិក្ខារ ដើម្បីបង្ការមហន្តរាយ ឬ ការពារសន្តិសុខ។
- ចលនវត្ថុដែលហាមឃាត់ មិនឱ្យរឹបអូសនេះ ក៏អាចត្រូវបានពង្រីកបានដែរ ដោយផ្អែកតាមស្ថានភាពជីវភាពរស់នៅ ឬ ស្ថានភាពពិសេសរបស់កូនបំណុលនៃការអនុវត្ត តាមរយៈដីកាសម្រេច តាមពាក្យសុំ (ម. ៣៨១ កថា. ១)។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- សាលាដំបូងដែលអាចអាជ្ញាសាលស្ថិតនៅ អាចអនុញ្ញាតឱ្យរឹបអូសនូវចលនវត្ថុដែលបានកំណត់ក្នុងមាត្រា ៣៨០ ដោយពិចារណាទៅលើជីវភាព ឬ ស្ថានភាពផ្សេងៗរបស់កូនបំណុលនៃការអនុវត្ត និង ម្ចាស់បំណុលនៃការអនុវត្តពាក្យសុំបាន (ម. ៣៨១ កថា. ១)។
- ស្ថានភាពទាំងនោះ អាចជា ម្ចាស់បំណុលនៃការអនុវត្ត មានជីវភាពរស់នៅធ្លាក់ចុះ ហើយទាមទារឱ្យអនុវត្តដោយបង្ខំដើម្បីទទួលបាននូវការគាំទ្រនូវជីវភាពរបស់ខ្លួន, ស្ថានភាពដែលកូនបំណុលនៃការអនុវត្តគ្មានឆន្ទៈក្នុងការអនុវត្តតាមកិច្ចសន្យាទាល់តែសោះជាដើម។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- សិទ្ធិលើបំណុលដែលហាមឃាត់មិនឱ្យរឹបអូស (ម, ៣៨២) រួមមាន៖

  ១. បៀវត្ស ប្រាក់ឈ្នួល និង សិទ្ធិលើបំណុលដែលមានលក្ខណៈដូចជាប្រាក់បៀវត្សផ្សេងទៀត អាចរឹបអូសបាន ចំពោះប្រាក់ដែលលក់ក្រោយពីបានកាត់នូវពន្ធអាករ និង ប្រាក់ធានារ៉ាប់រងសង្គមកិច្ច ពីចំនួនទឹកប្រាក់ដែលកូនបំណុលនៃការអនុវត្តត្រូវសងសំណង នៅពេលកំណត់ដែលត្រូវសងនោះ លុះត្រាតែស្របតាមចំណុចនីមួយៗដែលកំណត់ដូចខាងក្រោមនេះ៖

  ក. ផ្នែកតិចជាង ឬ ស្មើនឹង ២០០,០០០ រៀល ក្នុងខែ ពុំអាចរឹបអូសបានទេ។

  ខ. ផ្នែកក្នុងខ្ទង់លើពី ២០០,០០០ រៀល ទៅដល់ ៦០០,០០០ រៀល ក្នុងមួយខែ ពុំអាចរឹបអូសលើពីចំនួនទឹកប្រាក់ ១ ភាគ ៤ នៃផ្នែកនេះទេ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

គ. ផ្នែកក្នុងខ្ទង់លើពី ៦០០,០០០ រៀល ទៅ ២,០០០,០០០ រៀល ក្នុងមួយខែ ពុំអាចរឹបអូសចំនួនទឹកប្រាក់ ១ ភាគ ៣ នៃផ្នែកនេះបានទេ។

ឃ. ផ្នែកក្នុងខ្ទង់លើពី ២,០០០,០០០ រៀល ទៅ ៤,០០០,០០០ រៀល ក្នុងមួយខែ ពុំអាចរឹបអូសចំនួនទឹកប្រាក់ ១ ភាគ ២ នៃផ្នែកនេះបានទេ។

ង. ផ្នែកក្នុងខ្ទង់លើពី ៤,០០០,០០០ រៀល ទៅ ៦,០០០,០០០ រៀល ក្នុងមួយខែ ពុំអាចរឹបអូសចំនួនទឹកប្រាក់ ២ ភាគ ៣ នៃផ្នែកនេះបានទេ។

ច. ផ្នែកលើសពី ៦,០០០,០០០ រៀល ក្នុង ១ ខែ អាចរឹបអូសយកបានទាំងអស់។

២. ចំពោះសិទ្ធិលើបំណុលចំពោះប្រាក់ឧបត្ថម្ភជីវភាព ប្រាក់ឧបត្ថម្ភផ្នែកសិក្សា ប្រាក់ឧបត្ថម្ភសុខភាព និង សិទ្ធិលើបំណុលផ្សេងទៀតដែលមានគោលបំណងការពារជីវភាពរបស់កូនបំណុលនៃការអនុវត្ត ពុំអាចរឹបអូសបានឡើយ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ទំហំ នៃសិទ្ធិលើបំណុលដែលហាមឃាត់ ដែលកំណត់ក្នុងមាត្រា ៣៨២ អាចត្រូវបានពង្រីកបន្ថែមទៀត ដោយដីកាសម្រេចរបស់តុលាការអនុវត្ត ដោយពិចារណាលើស្ថានភាពជីវភាព ឬ ស្ថានភាពផ្សេងរបស់កូនបំណុលនៃការអនុវត្ត តាមពាក្យសុំបាន។ (ម. ៣៨៣)
- ទំហំ នៃសិទ្ធិលើបំណុលដែលហាមឃាត់ ដែលកំណត់ក្នុងមាត្រា ៣៨២ ក៏អាចត្រូវបានរឹបអូស ក្នុងករណីមានដីកាសម្រេចរឹបអូស របស់តុលាការអនុវត្ត ដោយពិចារណាលើស្ថានភាពជីវភាព ឬ ស្ថានភាពផ្សេងរបស់កូនបំណុលនៃការអនុវត្ត តាមពាក្យសុំបាន។ (ម. ៣៨៣)

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ការរឹបអូសប្រាក់ឈ្នួលអនុលោមតាមច្បាប់ការងារ ១៩៩៧
  - ការរឹបអូសប្រាក់ឈ្នួល ត្រូវអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន (ម. ១៣៣ នៃច្បាប់ការងារ)។
  - ប្រាក់វិភាគគ្រួសារ មិនអាចរឹបអូសបានទេ លើកលែងតែវិភាគនោះសម្រាប់ទុកសងថ្លៃអាហារ (ម. ១៣២ នៃច្ប.ការងារ)
  - ប្រាក់ឈ្នួលដែលតិចជាង ឬ ស្មើប្រាក់ឈ្នួលអប្បបរមាដែលត្រូវបានធានា មិនអាចរឹបអូសបានឡើយ។
  - ភាគប្រាក់ឈ្នួលដែលលើសពី ១ ដល់ ៣ ដងនៃប្រាក់ឈ្នួលអប្បបរមាដែលត្រូវធានា អាចរឹបអូសបានតែ ២០ % នៃប្រាក់ឈ្នួលតែប៉ុណ្ណោះ។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ការរឹបអូសប្រាក់ឈ្នួលអនុលោមតាមច្បាប់ការងារ ១៩៩៧
  - ប្រាក់ឈ្នួលដែលលើពី ៣ ដល់ ១០ ដងនៃប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានធានានោះ អាចរឹបអូសបានតែតែ ៣០ ភាគរយនៃប្រាក់ឈ្នួលនោះតែប៉ុណ្ណោះ។
  - ប្រាក់ឈ្នួលដែលលើពី ១០ ដង នៃប្រាក់ឈ្នួលអប្បបរមា ដែលត្រូវបានធានានោះ អាចរឹបអូសបានតែតែ ៥០ ភាគរយនៃប្រាក់ឈ្នួលនោះតែប៉ុណ្ណោះ។
  - បញ្ជាក់៖ ប្រាក់ឈ្នួលដែលយកមកគិតគូរនេះត្រូវគិតតែប្រាក់ឈ្នួលប្រចាំខែ (ម. ១៣០ នៃច្បាប់ការងារ)។

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ការហាមមិនឱ្យរឹបអូសហួសប្រមាណ (ម. ៣៩១)
  - អនុវត្តចំពោះការរឹបអូសចំពោះចលនវត្ថុ
  - មិនត្រូវរឹបអូសចលនវត្ថុ ហួសកម្រិតចាំបាច់សម្រាប់សងសំណង សិទ្ធិលើបំណុល និង សោហ៊ុយសម្រាប់ការអនុវត្ត។
  - ប្រសិនបើរឹបអូសលើស អាជ្ញាសាលា ត្រូវលុបចោលការរឹបអូស ត្រឹមផ្នែកដែលបានរឹបអូសហួសកម្រិត។
- ការហាមឃាត់មិនឱ្យរឹបអូស ក្នុងករណីដែលប៉ាន់ប្រមាណឃើញថាគ្មានចំនួនសេសលស់៖ ក្រោយពីបានបង់សោយហ៊ុយសម្រាប់នីតិវិធីហើយ។ (ម. ៣៩២)

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ទ្រព្យសម្បត្តិ និង សិទ្ធិរបស់តតិយជន មិនមែនជាទ្រព្យសម្បត្តិទទួលខុសត្រូវទេ ។ តតិយជនអាចតតាំងលុះត្រាតែតតិយជនបានបំពេញនូវលក្ខខណ្ឌតតាំងដែលតម្រូវដោយក្រមរដ្ឋប្បវេណី ឧទា. លក្ខខណ្ឌតតាំងដោយការចុះបញ្ជី ចំពោះការផ្ទេរសិទ្ធិលើអចលនវត្ថុ (ម. ១៣៤ នៃក្រមរដ្ឋប្បវេណី)។ ប៉ុន្តែករណីនេះ ក៏មិនរារាំងក្នុងការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលនៃការអនុវត្ត ក្នុងការអនុវត្តសិទ្ធិលុបចោលនូវសកម្មភាពដែលនាំឱ្យខូចប្រយោជន៍ (ម. ៤២៨ នៃក្រមរដ្ឋប្បវេណី)។
- នៅក្នុងការអនុវត្តដោយបង្ខំចំពោះសិទ្ធិទាមទារឱ្យប្រគល់វត្ថុ កម្មវត្ថុនៃការអនុវត្តគឺវត្ថុដែលកូនបំណុលកាន់កាប់ ឬ សិទ្ធិទាមទារឱ្យប្រគល់ដែលកូនបំណុលមានចំពោះតតិយជន (ម. ៥២៦)

# វិសាលភាពនៃទ្រព្យសម្បត្តិទទួលខុសត្រូវ (ត)

- ជាទូទៅ ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវកំណត់នៅក្រោមច្បាប់សារធាតុ។
- ស្ថាប័នអនុវត្ត (ជាពិសេសអាជ្ញាសាលា) ពុំចាំបាច់ធ្វើការស្រាវជ្រាវថាតើទ្រព្យសម្បត្តិណាជាទ្រព្យសម្បត្តិទទួលខុសត្រូវឬទេ ពុំដូចនោះទេ ជាលទ្ធផល ស្ថាប័នអនុវត្តនឹងរារែកក្នុងអនុវត្ត និង ពិបាកក្នុងការចាប់ផ្ដើមអនុវត្ត ឱ្យឆាប់រហ័ស។ ហើយម្យ៉ាងវិញទៀត ក៏បើកផ្លូវឱ្យតតិយជនដែលប៉ះពាល់សិទ្ធិ អាចប្ដឹងតវ៉ាដោយតតិយជនបានដែរ (ម. ៣៦៥)

# ការទទួលខុសត្រូវដោយមានកម្រិត

- ជាគោលការណ៍ នៅក្នុងការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យសងជាប្រាក់ ម្ចាស់បំណុលមានសិទ្ធិជ្រើសរើសទ្រព្យសម្បត្តិដើម្បីរឹបអូស ពីក្នុងចំណោមទ្រព្យសម្បត្តិទទួលខុសត្រូវ។
- ប៉ុន្តែចំពោះការអនុវត្តដោយបង្ខំ ដែលមានគោលបំណងឱ្យជាប្រាក់មួយចំនួន ទ្រព្យសម្បត្តិទទួលខុសត្រូវ ត្រូវបានកម្រិតត្រឹមវត្ថុ ឬ ទ្រព្យជាក់លាក់ នៅក្នុងទំហំជាក់លាក់។
- ឧទា. សន្តតិជនទទួលបន្តនូវទ្រព្យសម្បត្តិរបស់មតកជន ម្ចាស់បំណុលនៃការអនុវត្តរបស់មតកជន អាចអនុវត្តដោយបង្ខំចំពោះសន្តតិជន ត្រឹមកម្រិតនៃមតិកតែប៉ុណ្ណោះ (ម. ១២៥៦ និង ១២៥៨ កថា ១ នៃក.រណ)

# ការទទួលខុសត្រូវដោយមានកម្រិត

- ការទទួលខុសត្រូវ មិនមែនជាការជាត់ចេញពីទ្រព្យទទួលខុស ដូចជាករណីទ្រព្យសម្បត្តិដែលហាមឃាត់មិនឱ្យរឹបអូសនោះទេ ដែលសញ្ញាណនេះទាញចេញពីច្បាប់សារធាតុ។ ហេតុដូចនេះ មិនមែនជាស្ថាប័នអនុវត្ត ត្រូវស្រាវជ្រាវនោះទេ។
- ហេតុដូចនេះ ហើយបានជាក្រមនីតិវិធីរដ្ឋប្បវេណី បើកផ្លូវឱ្យមានការប្ដឹងតវ៉ាចំពោះការអនុវត្ត ឬបណ្ដឹងតវ៉ាដោយតតិយជន។

# សូមអរគុណ!